# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាបុណ្យភ្ជុំនៅផ្សារតូច
# ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៨

*តើអ្នកបានបម្រើ និងស្រឡាញ់បងប្អូនឯទៀតៗដល់កម្រិតណា?*

អត្ថបទទី១៖ កាឡ ១,១៣-២៤
ដំណឹងល្អ៖ លក ១០,៣៨-៤២

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះយើងគោរពបុណ្យភ្ជុំធំនៅប្រទេសកម្ពុជា សម្រាប់យើងជាគ្រីស្តបរិស័ទយើងត្រូវតែគិតពិចារណាអំពីជំនឿរបស់យើង។ ជំនឿយើង វាចូលជាមួយប្រពៃណីដែលយើងមាននៅក្នុងប្រទេសកម្ពុជា ជាពិសេសអគ្គសញ្ញាអាពាហ៍ពិពាហ៍យើងយកប្រពៃណីខ្លះចូលគ្នា និងបុណ្យភ្ជុំនេះ។ ជាទូទៅក្នុងសាសនាកាតូលិក យើងគោរពបងប្អូនដែលបានស្លាប់នៅថ្ងៃទី០២ ខែវិច្ឆិកា និងយើងគោរពសន្តបុគ្គលទាំងឡាយនៅថ្ងៃទី០១ ខែវិច្ឆិកា ដើម្បីនឹកឃើញព្រះជាម្ចាស់បានរៀបចំផ្លូវយ៉ាងពិសេស សម្រាប់មនុស្សដែលដើរតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ឲ្យទទួលជីវិតអស់កល្បជានិច្ចនៅស្ថានបរមសុខ។ សន្តសន្តីបុគ្គល ជាអ្នកដែលមានឈ្មោះជាផ្លូវការនៅក្នុងបញ្ជីព្រះសហគមន៍ និងមានមួយចំនួនទៀតបានជាប់ជាមួយព្រះជាម្ចាស់អស់ហើយដែលយើងមិនស្គាល់ ដោយបានយកចិត្តទុកដាក់ដើរតាមព្រះជាម្ចាស់។ ព្រះសហគមន៍កាតូលិកនៅកម្ពុជា យើងបានសម្រេចចិត្តថាយើងធ្វើបុណ្យសម្រាប់មរណបុគ្គល នៅថ្ងៃតែមួយជាមួយថ្ងៃបុណ្យភ្ជុំ។

យើងត្រូវការគិតពិចារណា អំពីជំនឿរបស់យើង យើងបានយកម្ហូបអាហារមកព្រះវិហារមិនមែនដើម្បីចិញ្ចឹមប្រេតឲ្យហូបឆ្អែតទេ តែជាថ្ងៃមួយដែលយើងត្រូវនឹកឃើញដល់ជំនឿរបស់យើងជាគ្រីស្តបរិស័ទខ្មែរ យើងដូចជាបងប្អូនប្រជាពលរដ្ឋខ្មែរទាំងអស់គោរពជីដូនជីតានិងបងប្អូនដែលទទួលមរណភាពហើយ។ សម្រាប់យើងដែលជាគ្រីស្តបរិស័ទខ្មែរ យើងនឹកឃើញដល់ជំនឿរបស់យើងដែលបានប្រកាសថា "**យើងជឿលើព្រះយេស៊ូគ្រីស្តដែលមានព្រះជន្មរស់ឡើងវិញ ខ្ញុំធ្វើអ្វីៗទាំងអស់សម្រាប់ព្រះជាម្ចាស់ រស់ក្តី ស្លាប់ក្តី សម្រាប់ព្រះជាម្ចាស់**"។ ពីថ្ងៃដែលយើងភ្ជាប់ជាមួយព្រះជាម្ចាស់តាមរយៈអគ្គសញ្ញាជ្រមុជទឹក ជីវិតរបស់យើងគឺសម្រាប់ព្រះជាម្ចាស់ ទាំងរស់ក្តី ទាំងស្លាប់ក្តី អ្វីៗទាំងអស់គឺសម្រាប់ព្រះជាម្ចាស់។ យើងជាគ្រីស្តបរិស័ទ មិនមែនជឿលើព្រះយេស៊ូដែលសោយទិវង្គត ប៉ុន្តែជឿលើព្រះយេស៊ូដែលសោយទិវង្គតលើឈើឆ្កាងនិងមានព្រះជន្មរស់ឡើងវិញ។ ដោយសារព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ណែនាំឲ្យយើងទាំងអស់ពោរពេញដោយសេចក្តីសង្ឃឹម ដោយសង្ឃឹមថានៅថ្ងៃណាមួយយើងអាចទទួលជីវិតអស់កល្បជានិច្ច

រួមជាមួយព្រះជាម្ចាស់នៅស្ថានបរមសុខ។ ហេតុនេះហើយពីសម័យដើម គ្រីស្តបរិស័ទអធិដ្ឋានសម្រាប់បងប្អូនដែលទទួលមរណភាពទាំងអស់ ដោយសារយើងមិនដឹងច្បាស់គេទៅណាប្រហែលមិនទាន់ទៅស្ថានបរមសុខភ្លាមៗ។ ប៉ុន្តែ ត្រូវការជម្រះចិត្តគំនិតថែមទៀតរួមជាមួយព្រះជាម្ចាស់ ជាមូលហេតុយើងថ្វាយអភិបូជាសម្រាប់អ្នកស្លាប់ យើងទូលអង្វរព្រះជាម្ចាស់ដើម្បីជួយអ្នកស្លាប់ហើយអាចជម្រះអ្វីៗទាំងអស់ ដើម្បីចូលនៅក្នុងពន្លឺដែលគ្មានព្រំដែន នៅក្នុងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ដ៏ពេញលក្ខណៈ។ សេចក្តីសង្ឃឹមរបស់យើង គឺនៅពេលយើងទទួលមរណភាពឲ្យយើងមើលឃើញព្រះជាម្ចាស់ ដែលយើងបានដើរតាមលើផែនដី ដែលយើងត្រូវការរៀបចំចិត្តគំនិត។ យើងបានអធិដ្ឋានសម្រាប់អ្នកស្លាប់ហើយ ប៉ុន្តែកុំឲ្យយើងភ្លេចខ្លួនឯងជាគ្រីស្តបរិស័ទ យើងធ្វើដូចម្តេចដើម្បីត្រៀមខ្លួនរៀបចំចិត្តគំនិត។

នៅក្នុងគម្ពីរដំណឹងល្អ "**ពេលកណ្តាលយប់ នៅពេលម្ចាស់ត្រឡប់មកវិញឃើញអ្នកបម្រើណានៅរង់ចាំលោក អ្នកបម្រើនោះមានសុភមង្គលហើយ**" ព្រះជាម្ចាស់ត្រឡប់មកវិញនៅថ្ងៃដែលយើងទទួលមរណភាព។ យើងមិនដឹងថាយើងទទួលមរណភាពនៅថ្ងៃណាទេ អ្វីដែលសំខាន់ពីមួយថ្ងៃទៅមួយថ្ងៃយើងជាអ្នកបម្រើ ដែលរៀបចំចិត្តគំនិត ដើម្បីទន្ទឹងរង់ចាំព្រះជាម្ចាស់យាងមក។ យើងរៀបចំចិត្តកំនិត ដើម្បីរស់នៅក្នុងព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ ឲ្យយើងឆ្លាក់ក្នុងចិត្តរបស់យើងធម៌វិន័យរបស់ព្រះយេស៊ូ។ ពីមួយថ្ងៃទៅមួយថ្ងៃ ពេលយើងស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ នៅពេលយើងអធិដ្ឋាននឹកឃើញដល់ព្រះជាម្ចាស់ នៅពេលយើងចូលព្រះវិហារដើម្បីទទួលអគ្គសញ្ញាលើកលែងទោស និងអគ្គសញ្ញាព្រះកាយព្រះគ្រីស្តពីព្រះជាម្ចាស់ នេះជាពេលវេលាដើម្បីនឹកឃើញអំពីឋានៈរបស់យើង គឺជាបុត្រាធីតារបស់ព្រះជាម្ចាស់ ដើម្បីរស់នៅតាមរបៀបព្រះយេស៊ូ។ ព្រះយេស៊ូណែនាំ ឲ្យយើងរស់នៅក្នុងសេចក្តីសង្ឃឹម យើងបានឃើញអំពីរបៀបដែលព្រះយេស៊ូបានធ្វើ។ ព្រះយេស៊ូបានចាត់ក្រុមសាវ័កទាំង៧២នាក់ ឲ្យចេញពីភូមិមួយទៅភូមិមួយ ដើម្បីសួរសុខទុក្ខតាមផ្ទះ ដើម្បីជួបជុំគ្នា ដើម្បីបរិភោគជាមួយគ្នា។ យើងជាគ្រីស្តបរិស័ទយើងរស់នៅក្នុងសង្គមបច្ចុប្បន្ននេះ ឲ្យយើងបង្កើតទំនាក់ទំនងជាមួយបងប្អូនឯទៀតៗ។

ព្រះយេស៊ូមានព្រះបន្ទូលថា "**សូមប្រគល់សេចក្តីសុខសាន្ត ឲ្យក្រុមគ្រួសារដែលបានទទួលស្វាគមន៍បងប្អូន**" សេចក្តីសុខសាន្តជាអ្វីដែលមនុស្សលោកចង់បាន។ ព្រះយេស៊ូមានព្រះបន្ទូលទៀតថា "**សូមប្រកាសអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ដែលជិតមកដល់**" ឲ្យអ្នកជំងឺជាសះស្បើយមើលសេចក្តីត្រូវការរបស់បងប្អូន។ យើងបានបង្ហាញជាក់ស្តែងអំពីសក្ខីភាពរបស់យោង តាមរយៈទំនាក់ទំនងដែលយើងបង្កើត នេះជារបៀបដែលព្រះយេស៊ូណែនាំឲ្យយើង ដើម្បីរៀបចំខ្លួនទទួលស្វាគមន៍ព្រះជាម្ចាស់ដែលយាងមក។ នៅក្នុងតុលាការរបស់ព្រះជាម្ចាស់ មានសំនួរតែ

មួយថា "**តើអ្នកបានបម្រើ និងស្រឡាញ់បងប្អូនឯទៀតៗដល់កម្រិតណា?**"។ យើងនឹកឃើញដល់ជំនឿរបស់យើង យើងមកទីនេះដើម្បីអធិដ្ឋាន ដើម្បីប្រកាសសារជាថ្មីខ្ញុំជឿលើព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ និងដើម្បីអធិដ្ឋានសម្រាប់យើងរៀងៗខ្លួន ឲ្យយើងមានកម្លាំងកាយកម្លាំងចិត្ត ឲ្យយើងរស់នៅក្នុងសេចក្ដីសង្ឃឹមតាមរបៀបព្រះយេស៊ូ ដើម្បីត្រៀមខ្លួនទទួលព្រហជាម្ចាស់ដែលយាងមកនៅក្នុងចុងក្រោយនៃជីវិតរបស់យើងនៅលើផែនដីនេះ។ យើងអព្រះគុណព្រះជាម្ចាស់ ដែលបានប្រទានព្រះយេស៊ូ ដើម្បីណែនាំឲ្យយើងចូលនៅក្នុងជីវិតអស់កល្បជានិច្ច យើងអរព្រះគុណព្រះជាម្ចាស់ សម្រាប់បងប្អូនរបស់យើងទាំងអស់ដែលទទួលមរណភាព សូមព្រះអង្គទទួលពួកគាត់នៅក្នុងសេចក្ដីសុខសាន្តរបស់ព្រះអង្គនៅស្ថានបរមសុខ។ អាម៉ែន៕